# សេចក្តីប្រកាសពត័មាន

## សន្និសិទអន្តរជាតិលើកទី៨ ផ្នែកសុខភាពសាធារណៈ នៃបណ្តាប្រទេសក្នុង មហាអនុ តំបន់ទន្លេមេគង្គ

## ការឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល: ការពង្រឹងគុណភាពនៃការថែទាំសុខភាព

សណ្ឋាគារសុខាភ្នំពេញ

**ថ្ងៃទី ០៥-០៦ ខែវិច្ឆិកា ឆ្នាំ២០១៦**

ជារៀងរាល់ឆ្នាំ មហាវិទ្យាល័យ សុខភាព សាធារណៈ នៃសកលវិទ្យាល័យ ចំនួន១៣ ដែលជាសមាជិក នៃបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ (ប្រទេស កម្ពុជា ខេត្តយូណាន-ចិន ឡាវ ភូមា ថៃ និងវៀតណាម) បានផ្លាស់ប្តូរវេនគ្នាដើម្បីប្រារព្ធនូវសន្និសិទអន្តរជាតិផ្នែកសុខភាព សាធារណៈ។ សន្និសិទនេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីលើកកំពស់ សមត្ថភាពសុខភាពសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការចាំបាច់សុខភាពសាធារណៈ នានាតាមរយៈការអប់រំសុខភាព លើកកំពស់សុខភាព ការស្រាវជ្រាវគោលនយោបាយសុខភាព និងការគាំទ្រ សំរាប់លើកកំពស់ សុខភាព និងសមភាពសុខភាព ប្រជាជន។

ឆ្នាំនេះ **វិទ្យាស្ថានជាតិសុខភាពសាធារ ណៈ នឹងប្រារព្ធនូវសន្និសិទអន្តរជាតិលើកទី៨ ផ្នែកសុខភាពសាធារណៈនៃបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ** ក្រោមប្រធានបទ **ការឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលៈ ការពង្រឹងគុណភាពនៃការថែទាំ សុខភាព**។ នេះជាលើកដំបូងសំរាប់ប្រទេសកម្ពុជាដែលនឹងប្រារព្ធនូវសន្និសិទក្នុង ជំនាញសុខភាពសាធារណៈ ដែលវិស័យនេះគឺហាក់ដូចជាថ្មី ចំពោះប្រជាជន និង សូម្បីតែ ក្នុងចំណោមអ្នកមានអាជីពវេជ្ជសាស្រ្ត ។ តាមពិតជំនាញសុខភាពសាធារណៈ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ និងចាំបាច់សំរាប់ ការងារក្នុងប្រពន្ធ័សុខាភិបាលនៃក្រសួងសុខាភិបាល។

ហេតុដូចនេះ ការប្រារព្ធសន្និសិទជាអន្តរជាតិលើផ្នែកសុខភាពសាធារណៈនេះ គឺជាឱកាសមាស សំរាប់វិទ្យាស្ថានជាតិសុខភាពសាធារណៈ ក្នុងការបង្ហាញពីតំរូវការចាំបាច់នៃជំនាញសុខភាពសាធារណៈ ដែលមាន តួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងសុខភាពប្រជាជនទាំងក្នុងប្រទេស និងក្នុងតំបន់។ សន្និសិទនេះ ក៏ជាចំនុចចាប់ផ្តើម សហការណ៏ជាមួយដៃគូផ្សេងៗ ក្នុងការធ្វើអោយវិស័យសុខភាពសាធារណៈ នៃប្រទេសកម្ពុជាមានភាពកាន់តែប្រសើរឡើង។

សន្និសិទអន្តរជាតិនេះ មានអ្នកចូលរួមសរុប ប្រមាណ៤០០នាក់ មកពីប្រទេសចំនួន២០។ ពួកគេ នឹង ជជែកពិភាក្សាគ្នា ចែករំលែកនូវជំនាញ បទពិសោធន៍ និងលទ្ធផលនៃការស្រាវជ្រាវថ្មីៗ។ អ្នកចូលរួមទាំងអស់ ជាសាស្រ្តាចារ្យ អ្នកស្រាវជ្រាវ និងជានិស្សិត មកពីបណ្តា សាលាសុខភាពសាធារណៈ ក្នុងបណ្តាប្រទេស ក្នុងមហាអនុតំបន់ទន្លេមេគង្គ។ យើងក៏បានអញ្ជើញវាគ្មិនជំនាញសុខភាពសាធារណៈមកពី អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធជំងឺឆ្លងសហរដ្ឋអាមេរិក ប្រទេសបែលហ្សិក អាឡឺម៉ង់ និងសិង្ហបូរី ដើម្បីចូលរួមចែករំលែកនូវបទពិសោធន៍ ដែលទាក់ទងនឹងប្រពន្ធ័សុខាភិបាល ការគ្របដណ្តប់សុខភាពជាសកកល ការគ្រប់គ្រងគុណភាពសេវាសុខភាព គោលនយោបាយគ្របដណ្តប់សុខភាពជាសកកល និងនិងការអនុវត្ត ការអប់រំ និងបណ្តុះបណ្តាលជំនាញសុខភាពសាធារណៈ និងឧបសគ្គនានាក្នុងការអនុវត្តន៍គោលនយោបាយសុខាភិបាល។

ជាសរុប យើងមានអ្នកសរសេរអត្ថបទវិទ្យាសាស្រ្តសង្ខេបចំនួន ១៨៥ ដែលទាក់ទងនឹងប្រធានបទផ្សេងៗគ្នា។ ប្រធានបទទាំងនោះរួមមានជំងឺឆ្លង និងជំងឺមិនឆ្លង ការធ្វើអន្តរាគមន៍សុខភាពសាធារណៈ និងការលើកកំពស់សុខភាព កត្តាប្រឈមមុខនៃសុខភាព ការគ្របដណ្តប់សុខភាពជាសកល និងគុណភាពនៃសេវាសុខាភិបាល។ ក្រៅពីនេះយើងមានអង្គប្រជុំពេញអង្គ ដែលមានការចូលរួមពីអ្នកជំនាញសុខភាពសាធារណៈ ដោយមានបង្ហាញ និងពិភាក្សា ពីចំនុចសំខាន់ទាក់ទងនឹងគោលនយោបាយ និងការគ្របដណ្តប់សុខភាពជាសកកល ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅឆ្នាំ២០៣០ បទពិសោធន៍ជាសកលក្នុងការសំរេចបាននូវសេវាគ្របដណ្តប់សុខភាពជាសកល គោលនយោបាយ

យុទ្ធសាស្ត្រ និង ឧបសគ្គរបស់កម្ពុជា ក្នុងការសំរេចបាននូវការគ្រប ដណ្តប់សុខភាពជាសកកល, ឧទាហរណ៍ ពីការអនុវត្តគោលការណ៍ធានាគុណភាពនៃការថៃទាំ និងការសំរេចបានដោយជោគជ័យនៅប្រទេសថៃ និងបទអន្តរាគមនិ ដោយអ្នកជំនាញដទៃទៀត ដែលនិយាយអំពីបទពិសោធន៏ ការលំបាក និងឧបសគ្គនានាក្នុងការអនុវត្តន៏ការងារ។

**ទំនាក់ទំនងបន្ថែម:**

**លោកសាស្ត្រាចារ្យរង បណ្ឌិតឈា ឆវណ្ណា**

**នាយកវិទ្យាស្ថានជាតិសុខភាពសាធារណ:**